ស.ប្រ.ក/លេខ ០៣/០៧ គ.យ.ស.ប/អ.ក

**សេចក្តីប្រកាសព័ត៌មាន**

**លទ្ធផលនៃការអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយ**

**ពីថ្ងៃទី ០១_៣១ មករា ឆ្នាំ២០០៧**

*ភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៧*

ក្នុងខែមករានេះ ខុមហ្វ្រែលបានធ្វើការអង្កេតទៅលើប្រព័ន្ធផ្សព្វផ្សាយទូរទស្សន៍ជាតិកម្ពុជា (ទទក) និងសារព័ត៌មានកោះសន្តិភាព និងរស្មីកម្ពុជា ទាក់ទងទៅនឹងការផ្សាយពីគណបក្សនយោបាយដែលឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ការរកឃើញមានដូចខាងក្រោមៈ

ការអង្កេតរបស់ខុមហ្វ្រែលទៅលើការផ្សាយរបស់ទូរទស្សន៍ជាតិកម្ពុជា (ទទក) ក្នុងខែមករា[១] បានបង្ហាញថា **ទទក មានភាពលំអៀងយ៉ាងខ្លាំងក្នុងការផ្សាយរបស់ខ្លួនទៅរកគណបក្សកាន់អំណាច ប្រជាជនកម្ពុជា** ដែលទទួលបានការផ្សព្វផ្សាយយ៉ាងច្រើនលើសលប់រហូតដល់៩២% (១ម៉ោង ២៩នាទី ៥០វិនាទី) នៃរយៈពេលសរុបដែលគណបក្សនយោបាយទាំងអស់ត្រូវបានលើកឡើង ឬផ្សាយដោយ ទទក (ចំនួននេះមានការធ្លាក់ចុះបើធៀបទៅនឹងការផ្សាយក្នុងសប្តាហ៍ទីមួយដែលមានរហូតដល់៩៩%)។

ការអង្កេតក៏បានបង្ហាញដែរថា ទទក បានផ្សព្វផ្សាយ និងលើកឡើងពីភាពវិជ្ជមានរបស់គណបក្សតែពីរ (គណបក្សប្រជាជនកម្ពុជា និងគណបក្សហ៊្វុនស៊ិនប៉ិច) ប៉ុណ្ណោះដែលកំពុងកាន់អំណាច ខណៈដែលភាពអវិជ្ជមានរបស់គណបក្សទាំងពីរមិនត្រូវបានឮឡើយ។ ក្នុងនោះគណបក្ស ប្រជាជនកម្ពុជា ទទួលបានការផ្សព្វផ្សាយបែបវិជ្ជមាននេះ ២១នាទី ០៥វិនាទី នៃការផ្សាយសរុបពីគណបក្សនេះ ខណៈដែលគណបក្សហ៊្វុនស៊ិនប៉ិចបាន ២០វិនាទី។ ការលើកឡើងពីភាពអវិជ្ជមាន មានចំពោះតែគណបក្ស **សម រង្ស៊ី** ប៉ុណ្ណោះ គឺ៥វិនាទីនៃរយៈពេលសរុបលើក ឡើងពីគណបក្សនេះ។ ចំណែកគណបក្សចំនួន៨ទៀតបានត្រឹមតែឮឈ្មោះប៉ុណ្ណោះ។

---

[១] ការផ្សាយពីម៉ោង ៥.០០ ដល់១១.០០យប់

ទទក ក៏បានចាក់ផ្សាយ**សម្ដីផ្ទាល់របស់មន្ត្រីគណបក្ស ប្រជាជនកម្ពុជា តែមួយគត់ដែលមានរយៈពេលសរុបចំនួន ១ម៉ោង ១នាទី ៤០វិនាទី** (ក្នុងនោះមានការលើកឡើងពីសមិទ្ធិផល ស្នាដៃ គុណបំណាច់ និង គោលជំហររបស់គណបក្ស ប្រជាជនកម្ពុជា)។ ក្រៅពីនេះ ទទក ក៏បានផ្សាយការស្រែកជ័យឃោស (ជយោ គណបក្សប្រជាជនកម្ពុជា) សំរាប់ គណបក្សប្រជាជនកម្ពុជា និងបានថតយកផ្លាកសញ្ញាគណបក្សនេះមកចាក់ផ្សាយផងដែរ ខណៈដែលគណបក្សផ្សេងចំនួន ១០ទៀតរួមទាំងគណបក្ស **ហ៊្វុនស៊ិនប៉ិច** ផងដែរនោះ មិនដែលត្រូវបានផ្សព្វផ្សាយ ឬបង្ហាញបែបនេះឡើយ។

មន្ត្រីមួយចំនួននៅក្នុងរាជរដ្ឋាភិបាល (ទាំងហ៊្វុនស៊ិនប៉ិច និងប្រជាជនកម្ពុជា) រួមទាំង សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុនសែនផងដែរ បានឆ្លៀតលើកឡើងពីគណបក្សរបស់ខ្លួនក្នុងពេលបំពេញភារកិច្ច ឬចូលរួមពិធីផ្សេងៗ។ ការផ្សាយរបស់ ទទក នៅថ្ងៃទី២៩ខែមករា ឆ្នាំ២០០៧ ស្ដីពីការប្រគល់សញ្ញាប័ត្រ បណ្ឌិតផ្នែកអប់រំដល់ សម្ដេចនាយករដ្ឋមន្ត្រីហ៊ុនសែន បានលើកឡើងពីជោគជ័យរបស់សម្ដេចដូចសព្វថ្ងៃនេះ ក៏ដោយសារតែមានការផ្ដល់ដំបូន្មានពីគណបក្ស ប្រជាជនកម្ពុជា ដែរ។

ដោយឡែកប្រព័ន្ធផ្សព្វផ្សាយបោះពុម្ព (កោះសន្តិភាព និងរស្មីកម្ពុជា) បានលើកឡើងពីគណបក្សនយោបាយ ធំៗចំនួន៤ប្រហាក់ប្រហែលគ្នា គឺគណបក្ស ប្រជាជនកម្ពុជា (៣២អត្ថបទ ស្មើនឹង៣៥%) គណបក្ស សម រង្ស៊ី (២១អត្ថបទ ស្មើនឹង២៣%) គណបក្ស នរោត្តម រណឫទ្ធិ (១៩អត្ថបទ ស្មើនិង២១% និងគណបក្ស ហ៊្វុនស៊ិនប៉ិច (១៤អត្ថបទ ស្មើនឹង១៥%)។ គណបក្សរណសិរ្សសង្គម ជាតិនិយម និងគណបក្សប្រជាជាតិខ្មែររួមគ្នាត្រូវបានផ្សាយចំនួន ៦% (៥អត្ថបទ)។

ទោះបីយ៉ាងណា ប្រព័ន្ធផ្សព្វផ្សាយបោះពុម្ពទាំងពីរមាននិន្នាការផ្សព្វផ្សាយតែពីភាពវិជ្ជមានរបស់គណបក្សកាន់ អំណាច **ប្រជាជនកម្ពុជា** ដែលទទួលបានរហូតដល់ទៅ ៧៨% (២៥អត្ថបទ) នៃចំនួនអត្ថបទសរុបនិយាយពីគណបក្សនេះ ដូចជា ការផ្សាយពីការបញ្ចូលសមាជិកថ្មី ស្នាដៃមេឃុំ ឬចៅសង្កាត់មកពីគណបក្ស ប្រជាជនកម្ពុជា និងការងារអភិវឌ្ឍន៍ នានារបស់គណបក្សនេះជាដើម (ភាពអវិជ្ជមានត្រូវបានលើកឡើងតែក្នុងអត្ថបទមួយប៉ុណ្ណោះ)។ ចំណែកគណបក្ស ដទៃទៀត ត្រូវបានផ្សព្វផ្សាយបែបអវិជ្ជមានច្រើនលើសលប់ (តិចបំផុត៥០%នៃចំនួនអត្ថបទសរុប ដែលគណបក្ស និមួយៗត្រូវបានផ្សាយ) ជាពិសេសជំលោះផ្ទៃក្នុង និងជំលោះរវាងគណបក្ស និងគណបក្ស។

**សូមអរគុណ!**

***សំរាប់ព័ត៌មានលំអិតសូមទាក់ទង:***


- លោក **គល់ បញ្ញា** នាយកប្រតិបត្តិ ខុមហ្វ្រែល ០១២ ៩៤២ ០១៧
- លោក **ម៉ារ សុផល** ប្រធានផ្នែកអង្កេត ខុមហ្វ្រែល ០១២ ៨៤៥ ០៩១
- លោក **កុយ ច័ន្ទដារិទ្ធ** ប្រធានផ្នែកព័ត៌មាន ខុមហ្វ្រែល ០១២ ៨៤៦ ២១១